## លក្ខខណ្ឌយោង (ទីប្រឹក្សាក្នុងស្រុក)

**តួនាទីៈ** មន្ត្រីជំនាញផ្នែកវិភាគចំណូល និងគោលនយោបាយសារពើពន្ធ

**ទីកន្លែងបម្រើការងារៈ** នាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ នៃអគ្គនាយកដ្ឋានគោល-នយោបាយ

### សាវតារ

អគ្គនាយកដ្ឋានគោលនយោបាយ ទទួលបន្ទុកលើការងារសម្របសម្រួល, ត្រួតពិនិត្យ និងវាយតម្លៃ(M&E) ការអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រកៀរគរចំណូល ២០១៩-២០២៣ និងការរៀបចំក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ព្រមទាំងការស្រាវជ្រាវផ្សេងៗទាក់ទងនឹងគោលនយោបាយចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ។

ដើម្បីធានាបាននូវប្រសិទ្ធភាពការងារពាក់ព័ន្ធនឹងការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល និងការរៀបចំក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យមអគ្គនាយកដ្ឋានមានតម្រូវការទីប្រឹក្សាក្នុងស្រុក ដែលមានឯកទេស ឬសមត្ថភាពពាក់ព័ន្ធនឹងការងារសម្របសម្រួល, តាមដាន និងវាយតម្លៃការរៀបចំ និងអនុវត្តយុទ្ធសាស្ត្រ ក៏ដូចជាជំនាញទាក់ទងនឹងរដ្ឋបាល និងគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ ព្រមទាំងការគ្រប់គ្រងក្របខណ្ឌចំណូល និងចំណាយ ។

### តួនាទី និងការទទួលខុសត្រូវ៖

- ធ្វើការសិក្សាស្រាវជ្រាវ, ធ្វើការស្ទង់មតិ, ប្រមូលទិន្នន័យ និងវិភាគទិន្នន័យ,
- វិភាគស្ថានភាពចំណូល និងគោលនយោបាយពន្ធ,
- រៀបចំសេចក្តីព្រាងគោលនយោបាយ ឬលទ្ធផលការសិក្សាដាក់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
- ធ្វើរបាយការណ៍អំពីវឌ្ឍនភាព និងការវាយតម្លៃលើលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល,
- ធ្វើការវិភាគគោលនយោបាយផ្សេងៗក្រោមការណែនាំរបស់លេខាធិការដ្ឋានត្រួតពិនិត្យ និងវាយតម្លៃ, និង
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាត់តាំងរបស់អគ្គនាយកដ្ឋាន ។

### ជំនាញ និងបទពិសោធន៍ការងារ៖

- មានសញ្ញាបត្របរិញ្ញាបត្រ ឬខ្ពស់ជាងនេះ ផ្នែកសេដ្ឋកិច្ច, ការគ្រប់គ្រងពាណិជ្ជកម្ម, គោលនយោបាយសាធារណៈ ឬសញ្ញាបត្រដែលមានតម្លៃប្រហាក់ប្រហែល,
- មានបទពិសោធន៍ការងារយ៉ាងហោច ០២ ឆ្នាំ ទាក់ទងនឹងការស្រាវជ្រាវ និងវាយតម្លៃ,
- មានបទពិសោធន៍ និងចំណេះដឹងទាក់ទងឧបករណ៍វាស់វែង(Tools), វិធីសាស្ត្រ(Methodologies), និងគោលការណ៍ (Principles) នៃការត្រួតពិនិត្យ និងវាយតម្លៃ (M&E),
- បង្ហាញសមត្ថភាពក្នុងការប្រមូល និងវិភាគទិន្នន័យ,
- មានជំនាញវិភាគគោលនយោបាយ និងដោះស្រាយបញ្ហាបានទាន់ពេលវេលា,
- មានលទ្ធភាពធ្វើការក្រោមសម្ពាធការងារ,

- ចេះធ្វើការងារជាក្រុម និងជំរុញក្រុមទាំងមូលឱ្យសហការគ្នា,
- មានសមត្ថភាពក្នុងការសរសេរនិងការនិយាយជាភាសាខ្មែរ និងអង់គ្លេស ។

ទីប្រឹក្សាក្នុងស្រុកនេះនឹងស្ថិតនៅក្រោមការដឹកនាំរបស់សេដ្ឋវិទូជាន់ខ្ពស់នៃអគ្គនាយកដ្ឋានគោលនយោបាយ និងអាចទទួលបានការបណ្តុះបណ្តាលបន្ថែមលើឯកទេសកម្មវិភាគរដ្ឋបាល និងគោលនយោបាយសារពើពន្ធ និងមិនមែនសារពើពន្ធ និងការរៀបចំក្របខណ្ឌហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ។